**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦ សសរ

# សេចក្តីសម្រេច

## ស្តីពី ការបង្កើតគណៈកម្មការបច្ចេកទេសផ្តល់យោបល់ លើគំរោងស្តីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញ កំណត់ហេតុនៃការចរចារលើគំរោងស្តីពី ការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និង រដ្ឋបាលសាធារណៈ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ រវាងព្រះរាជាណាចក្រកម្ពុជា និង សមាគមអភិវឌ្ឍន៍អន្តរជាតិ

# សំរេច

**ប្រការ ១.-** ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសមួយ នៅអមអ្នកសំរបសំរួលគំរោង ដើម្បីផ្តល់យោបល់បច្ចេកទេស លើគំរោងស្តីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលសាធារណៈ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ២.-** សមាសភាពគណៈកម្មការបច្ចេកទេសនេះ មានដូចខាងក្រោម :

| | |
|---|---|
| ១- អគ្គលេខាធិការ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | ប្រធាន |
| ២- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- តំណាង ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- តំណាង ក្រសួង ផែនការ | សមាជិក |
| ៥- តំណាង ក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ៦- តំណាង ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា | សមាជិក |
| ៧- តំណាង រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ | សមាជិក |
| ៨- តំណាង សាលាភូមិន្ទរដ្ឋបាល | សមាជិក |
| ៩- តំណាង វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- តំណាង រាជបណ្ឌិតសភាកម្ពុជា | សមាជិក |

**ប្រការ ៣.-** គណៈកម្មការបច្ចេកទេស ដឹកនាំដោយប្រធានមួយរូប ។ គណៈកម្មការបច្ចេកទេសដំណើរការការងារ ក្រោមការដឹកនាំរបស់ប្រធាន និង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។ ប្រធានគណៈកម្មការបច្ចេកទេស កោះប្រជុំសមាជិកតាមតំរូវការចាំបាច់ ។

**ប្រការ ៤.-** គណៈកម្មការបច្ចេកទេសមានភារកិច្ចផ្តល់យោបល់ជូនអ្នកសំរបសំរួលគំរោង លើការអនុវត្តន៍គំរោងស្តីពីការពង្រឹងសមត្ថភាព ផ្នែកសេដ្ឋកិច្ច និង រដ្ឋបាលសាធារណៈ ជាពិសេស ការរៀបចំកម្មវិធី និងសកម្មភាពបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល ការពង្រីកបន្ថែមចំនួនមន្ត្រីរាជការចូលរួមបណ្តុះបណ្តាល និង សកម្មភាពថ្មីៗផ្សេងទៀត ដូចជា ការរៀបចំសិក្ខាសាលាបន្ថែមទៀត ។

ប្រការ ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សា អាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេច នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជា ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*

*កាលប្បវត្តិ-ឯកសារ*